# ទំនាក់ទំនងកម្ពុជា-វៀតណាម៖ សមមិត្តរួមសមរភូមិនិងរបត់ថ្មី

*កម្ពុជា-វៀតណាម ជាប្រទេសដែលស្ថិតនៅក្នុងឧបទ្វីបឥណ្ឌូចិនជាមួយគ្នា។ ប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរតែងតែមានទំនាក់ទំនងគ្នា ផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធលើគ្រប់កាលៈទេសៈ និងជួយជ្រោមជ្រែងគ្នាយកឈ្នះលើបញ្ហាប្រឈម និងទុក្ខលំបាកនានា ដោយជួយជំរុញឱ្យមានការបោះជំហានទៅមុខ ដើម្បីឈានទៅរកការអភិវឌ្ឍ និងសមាហរណកម្មនៅក្នុងតំបន់។ ប្រទេសទាំងពីរបានឆ្លងកាត់ភ្លើងសង្គ្រាមជាមួយគ្នាតាំងពីដើមរៀងមក។ រហូតមកទល់បច្ចុប្បន្ន ប្រទេសទាំងពីរនៅតែរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺដ៏កាចសាហាវជាមួយបណ្ដាប្រទេសនានានៅក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនឹងការរួមគ្នាទប់ស្កាត់ការរីករាលដាលដ៏កាចសាហាវជាសកលនៃវីរុសកូវីដ-១៩ ប្រទេសទាំងពីរនៅតែប្រកាន់ខ្ជាប់នូវ កិច្ចព្រមព្រៀងអភិវឌ្ឍទំនាក់ទំនងទ្វេភាគី ក្នុងដំណាក់កាលថ្មី ក្រោមបាវចនា «ភាពជាអ្នកជិតខាងល្អ មិត្តភាពប្រពៃណី សហប្រតិបត្តិការលើគ្រប់ជ្រុងជ្រោយ-ស្ថិរភាពយូរអង្វែង» ដែលបានដាក់ចេញរួមគ្នាតាំងពីឆ្នាំ២០០៥មកដរាបរៀងមក។*

*ក្នុងអំឡុងសង្គ្រាមវៀតណាមឬសង្គ្រាមឥណ្ឌូចិនលើកទី២ ប្រទេសកម្ពុជាបានរួមចំណែកយ៉ាងធំធេងក្នុងការជួយជ្រោមជ្រែងដល់ការតស៊ូផ្ដួលរំលំរបបចក្រព័ទ្ធនិយម និងបានឈានទៅរំដោះបានទឹកដីភាគខាងត្បូង កសាងបានឯកភាពជាតិរហូតមកទល់សព្វថ្ងៃ។*

*ក្នុងនាមប្រទេសភូមិផងរបងជាមួយគ្នា តើកម្ពុជាបានរួមចំណែកអ្វីខ្លះក្នុងការជួយឱ្យវៀតណាមទទួលបានជោគជ័យក្នុងការបណ្ដេញពួកចក្រព័ទ្ធនិយម និងរំដោះបានវៀតណាមខាងត្បូង ក្នុងសម័យសង្គ្រាមវៀតណាម អំឡុងឆ្នាំ១៩៥៥-១៩៧៥ តើទំនាក់ទំនងរវាងប្រទេសទាំងពីរមានការវិវត្តយ៉ាងដូចម្ដេចក្នុងដំណាក់កាលថ្មីនេះ?*

*នៅពាក់កណ្ដាលទសវត្សឆ្នាំ១៩៦០ សង្គ្រាមដែលបង្កឡើងដោយសហរដ្ឋអាម៉េរិក ជាមួយវៀតណាម នៅវៀតណាមភាគខាងត្បូង បានរីករាលដាលបន្តិចម្ដងៗ ស្ទើរតែពាសពេញតំបន់ឥណ្ឌូចិន។ ប្រជាជនកម្ពុជា វៀតណាម និងឡាវ ដែលធ្លាប់បានរួបរួមគ្នាជាប្រពៃណី ក្នុងការប្រយុទ្ធប្រឆាំងនឹងសត្រូវរួម ក្នុងអំឡុងនៃសង្គ្រាមតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង ម្ដងរួចមកហើយនោះ ជាថ្មីម្ដងទៀតក៏បានឈរកៀកស្មាគ្នាយ៉ាងជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមកប្រឆាំងនឹងសហរដ្ឋអាម៉េរិក។*

ដើម្បីបង្ហាញស្មារតីសាមគ្គីភាព ប្រឆាំងនឹងសហរដ្ឋអាម៉េរិក ចាប់ពីថ្ងៃទី១ដល់ទី៩ ខែមីនា ឆ្នាំ១៩៦៩ សន្និសីទប្រជាជននៃប្រទេសទាំងបីនៅឥណ្ឌូចិន (កម្ពុជា វៀតណាម ឡាវ) បានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ (កម្ពុជា) ក្រោមគំនិតផ្តួចផ្តើមរបស់សម្តេចនរោត្តមសីហនុ ។ អង្គសន្និសីទបានអនុម័តនូវសេចក្តីសម្រេចចិត្តរួមមួយ ដែលបង្ហាញយ៉ាងច្បាស់នូវស្មារតីសាមគ្គីភាព និងការតស៊ូប្រឆាំងនឹងចក្រពត្តិនិយមអាម៉េរិកាំង របស់ប្រជាជននៃប្រទេសទាំងបីនៅឥណ្ឌូចិន។ អង្គប្រជុំបានសង្កត់ធ្ងន់លើ «ភាពចាំបាច់សម្រាប់ការពង្រឹងឥទ្ធិៈ ក្នុងការបង្រួបបង្រួមសាមគ្គីភាពដ៏ស្មោះត្រង់ និងប្រកបដោយនិរន្តរភាពរបស់ប្រជាជននៅឥណ្ឌូចិន» ក្នុងការតស៊ូប្រឆាំងនឹងសត្រូវរួម។

បន្ទាប់ពីសន្និសីទបីប្រទេសបានបញ្ចប់ ទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរណសិរ្សរំដោះជាតិដើម្បីរំដោះវៀតណាមខាងត្បូង និងព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយ សម្តេច នរោត្តម សីហនុ ត្រូវបានពង្រឹងកាន់តែខ្លាំងឡើងថែមទៀត។

ភាគីទាំងពីរគាំទ្រនិងទទួលស្គាល់គ្នាទៅវិញទៅមក។ ប្រទេសវៀតណាមទទួលស្គាល់និងគោរពអធិបតេយ្យភាព ឯករាជ្យភាព អព្យាក្រឹតភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាគាំទ្រជាមួយវៀតណាម គាំទ្រសង្គ្រាមតស៊ូប្រឆាំងនឹងសហរដ្ឋអាម៉េរិក ដើម្បីជួយសង្គ្រោះប្រទេស និងប្រជាជនវៀតណាម (នាគ្រានោះ នៅដើមខែសីហា ឆ្នាំ១៩៦៣ ព្រះរាជាណាចក្រកម្ពុជាបានផ្តាច់ទំនាក់ទំនងការទូតជាមួយរដ្ឋាភិបាលសៃហ្គន) ។

នៅថ្ងៃទី ២៤ ខែមិថុនាឆ្នាំ ១៩៦៧ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងព្រះរាជាណាចក្រកម្ពុជា បានភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការជាមួយគ្នា ក្រោយរណសិរ្សរំដោះជាតិដើម្បីរំដោះវៀតណាមខាងត្បូង បង្កើតការិយាល័យតំណាងអចិន្ត្រៃយ៍របស់ខ្លួននៅរាជធានីភ្នំពេញ តែប៉ុន្មានថ្ងៃប៉ុណ្ណោះ ។

ការបង្កើតទំនាក់ទំនងការទូតផ្លូវការរវាងកម្ពុជា និងវៀតណាម បានបង្កើតជាមូលដ្ឋាន និងជំនឿទុកចិត្ត ដើម្បីលើកទឹកចិត្តប្រជាជននៃប្រទេសទាំងពីរពង្រឹងសាមគ្គីភាពបន្ថែមទៀតក្នុងការប្រយុទ្ធនិងជួយគ្នានៅក្នុងសង្គ្រាមតស៊ូប្រឆាំងនឹងការឈ្លានពានរបស់បរទេស ហើយចុងក្រោយ ទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រនៅខែមេសា ឆ្នាំ១៩៧៥ ។

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនៃសង្គ្រាមនេះ ប្រសិនបើគ្មានការជួយឧបត្ថម្ភ គាំទ្រដ៏ថ្លៃថ្លា និងប្រកបដោយសុច្ឆន្ទៈពីថ្នាក់ដឹកនាំ និងប្រជាជនកម្ពុជាទេ នោះមិនដឹងថា ប្រទេសវៀតណាមត្រូវ

លះបង់សាច់ស្រស់ ឈាមស្រស់ និងពេលវេលាប៉ុន្មានបន្ថែមទៀតនោះទេ ដើម្បីស្ថាបនាបានផ្លូវទ្រៀងសឺន (Truong Son)ឬផ្លូវលំហូជីមិញ ដ៏អស្ចារ្យនេះ និងឈានទៅទទួលបានជ័យជំនះជាប្រវត្តិសាស្ត្រ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ នោះទេ។




ផ្លូវទ្រៀងសឺនឬផ្លូវលំហូជីមិញ (ប្រភព៖ National Museum of United States Air Force)

*សូមរំលឹកថា ផ្លូវទ្រៀងសឺនឬផ្លូវលំហូជីមិញ មានបណ្តោយសរុបប្រវែង១៧ពាន់គីឡូម៉ែត្រ ត្រូវបានកសាងឡើងតាំងពីឆ្នាំ១៩៥៩។ ក្នុងរយៈពេល១៦ឆ្នាំ (១៩៥៩-១៩៧៥) នៃសង្គ្រាមវៀតណាម ផ្លូវនេះជាកត្តា១ ក្នុងចំណោមកត្តាយុទ្ធសាស្ត្រដ៏មានអត្ថន័យជាច្រើនទៀត ដែលជួយឱ្យប្រទេសវៀតណាមបានទទួលឯកភាពប្រទេសជាតិ។ ផ្លូវនេះ បំបែកមកប្រទេសសកម្ពុជា នៅត្រង់ខ្ពង់រាប* Boloven *ភាគខាងត្បូងខេត្ត* Attapeu *និង* Muong May *ហើយត្រូវបានអ្នកខ្លះហៅថា ផ្លូវលំស៊ីហនុ។ ផ្លូវលំនេះមានតួនាទីយ៉ាងសំខាន់ សម្រាប់ទីក្រុងហាណូយ ក្នុងការដឹកជញ្ជូនកងទ័ពរបស់ខ្លួន មកប្រឆាំងនឹងសហរដ្ឋអាម៉េរិក ក្នុងកំឡុងសង្គ្រាមវៀតណាម ដើម្បីដឹកជញ្ជូនកងទ័ព និងស្បៀងអាហារ មកកាន់ភាគខាងត្បូងវៀតណាម ក្នុងសម័យសង្គ្រាមវៀតណាម នៅពេលដែលប្រទេសនេះត្រូវបានបែងចែកជា២។ ទំនិញ និងសម្ភារៈបរិក្ខារនានា ដែលបញ្ជូនពីខាងជើង មកកាន់ភាគខាងត្បូង ត្រូវដឹកតាមកប៉ាល់ដែលប្រើទង់ជាតិរបស់ប្រទេសសង្គមនិយម ចូលមកកំពង់ផែក្រុងព្រះសីហនុ បន្ទាប់មក ដឹកជញ្ជូនឆ្លងកាត់ប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់ដល់កងទ័ពនៅភាគខាងត្បូងនៃប្រទេសវៀតណាម។ ចំណែក នៅរដូវក្តៅនាឆ្នាំ១៩៦៩ ការផ្គត់ផ្គង់រហូតដល់៨០% សម្រាប់គោលដៅនៅសមរភូមិភាគខាងត្បូងនៃវៀតណាមខាងត្បូង ត្រូវដឹកឆ្លងកាត់កំពង់ផែក្រុងព្រះសីហនុរបស់កម្ពុជា។ នេះបើតាមសារព័ត៌មាន* Su Kien va Nhan Chung *របស់វៀតណាម។*

*ក្រោយកម្ពុជាចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (២៣ តុលា ១៩៩១) ទំនាក់ទំនងកម្ពុជា-វៀតណាម កាន់តែបោះជំហានអភិវឌ្ឍន៍ថ្មី។ ភាគីទាំងពីរតែងតែមានការផ្លាស់ប្តូរគ្នា គាំទ្រគ្នា និងជួយគ្នាទៅវិញទៅមក ទាំងក្នុងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមជាច្រើន។ រដ្ឋាភិបាល និងប្រជាជនកម្ពុជានៅតែបន្តជួយវៀតណាម ក្នុងការសម្របសម្រួលការរៀបចំកម្លាំងល្បាត រក្សាសន្តិសុខសណ្តាប់ធ្នាប់នៅតាមតំបន់ព្រំដែន និងជាពិសេសស្រាវជ្រាវ និងរុករកអធិជាតុយុទ្ធជនវៀតណាមដែលបានពលីជីវិតនៅលើទឹកដីកម្ពុជា។*

*ក្នុងការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមតំបន់ព្រំដែន ភាគីទាំងពីរបានឯកភាពជំរុញ ឱ្យមានកិច្ចសហប្រត្តិការជាមួយគ្នាយ៉ាងសកម្ម ក្នុងការរៀបចំកម្លាំងល្បាត ការពារសន្តិសុខ និងសុវត្ថិភាពនៅតាមតំបន់ព្រំដែនជាប្រចាំ។ ចាប់តាំងពីឆ្នាំ២០០០ មក ភាគីទាំងពីរបានអនុវត្តយ៉ាងទៀងទាត់នូវកិច្ចប្រជុំវិលជុំនៅតំបន់ជាប់ព្រំដែន ដើម្បីពិភាក្សានិងផ្លាស់ប្តូរយោបល់អំពីស្ថានភាព និងដោះស្រាយបញ្ហាប្រឈមនានានៅតាមព្រំដែន ដោយពង្រឹងទំនាក់*

ទំនងក្នុងភាពអ្នកជិតខាងល្អ បង្កើនការទុកចិត្តគ្នាទៅវិញទៅមក រួមចំណែកធ្វើឱ្យមានស្ថិរភាពស្ថានភាពនយោបាយ និងសង្គម ដើម្បីកសាងព្រំដែន ដែលប្រកបដោយមិត្តភាព និងសន្តិភាព។

ក្នុងការងារគោលនយោបាយ ជាពិសេសការរុករកអធិជាតុយុទ្ធជនវៀតណាម រដ្ឋាភិបាល និងប្រជាជនកម្ពុជា បានជួយជ្រោមជ្រែងវៀតណាមប្រកបដោយប្រសិទ្ធភាព។ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ ក្រោយរដ្ឋាភិបាលនៃប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការស្វែងរកនិងការធ្វើមាតុភូមិនិវត្តន៍ អធិជាតុកងទ័ពវៀតណាម ដែលត្រូវបានបាត់បង់ជីវិតក្នុងអំឡុងសង្គ្រាមនៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល គិតចាប់ពីឆ្នាំ២០០១ រហូតមកទល់ពេលនេះ ក្រុមរុករកបានរកឃើញនិងធ្វើមាតុភូមិនិវត្តន៍អធិជាតុយុទ្ធជនវៀតណាមយោធភូមិភាគទី៧ បានចំនួន ៩ ៦៥៣។

ឆ្នាំ១៩៩៩ កម្ពុជា-វៀតណាម បានព្រមព្រៀងអភិវឌ្ឍទំនាក់ទំនងទ្វេភាគី ក្នុងដំណាក់កាលថ្មី ក្រោមបាវចនា «ភាពជាអ្នកជិតខាងល្អ មិត្តភាពប្រពៃណី សហប្រតិបត្តិការលើគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង»។

មិត្តភាពជាអ្នកជិតខាង ទាំងការលះបង់ ទាំងការជួយគ្នាទៅវិញទៅមក បានក្លាយជាចំណុចលេចធ្លោក្នុងទំនាក់ទំនងកម្ពុជា-វៀតណាម ។ ទាំងប្រជាជនកម្ពុជា ទាំងវៀតណាមមានសំណាងណាស់ដែលមានមិត្តល្អក្នុងគ្រាលំបាកបំផុត។

ប្រទេសកម្ពុជា ជាទីតាំងដ៏សំខាន់មួយនៅក្នុងនយោបាយការបរទេសរបស់វៀតណាម ដោយសារតែមានតម្រូវការផ្នែកសេដ្ឋកិច្ច ដែលផ្សារភ្ជាប់នឹងផលប្រយោជន៍ផ្នែកសន្តិសុខនយោបាយ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់។ ប្រទេសកម្ពុជាដើរតួនាទីជាច្រកចេញចូលមួយនៅទិសខាងលិច ដើម្បីជួយប្រទេសវៀតណាម ក្នុងការជ្រៀតចូលទៅតំបន់នានា ដែលឆ្លងកាត់តំបន់អាស៊ី ចំណែកប្រទេសវៀតណាម ជាស្ពានសម្រាប់ចម្លងប្រទេសកម្ពុជាឆ្ពោះទៅទិសខាងកើត ដើម្បីពង្រីកទំនាក់ទំនងអន្តរជាតិ តាមរយៈផ្លូវពាណិជ្ជកម្មតាមច្រកសមុទ្រ។ ដូច្នេះ ទោះបីចង់ឬមិនចង់ និងស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ប្រទេសកម្ពុជា និងប្រទេសវៀតណាម នៅតែមិនអាចបំបែកបំបាក់បាន និងមានទំនាក់ទំនងគ្នាទៅវិញទៅមកជានិច្ចនិរន្តរ៍។

បន្ទាប់ពីបក្សកុម្មុយនីស្តវៀតណាមបានបញ្ចប់ មហាសន្និបាតបក្សទូទាំងប្រទេសលើកទី១៣ ដោយជោគជ័យ សមត្ថេច នាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាប្រធានគណបក្សប្រជាជនកម្ពុជា បានហៅទូរស័ព្ទទៅអបអរសាទរ ដល់លោកអគ្គលេខាធិការបក្ស លោក Nguyen Phu Trong

លោក Nguyen Xun Phuc ប្រធានរដ្ឋ និងលោក Pham Ninh Chinh នាយករដ្ឋមន្ត្រីរបស់វៀតណាមផងដែរ។

ទំនាក់ទំនងនិងសហប្រតិបត្តិការរវាងគណបក្សប្រជាជនកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាម ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះបានពង្រឹង និងអភិវឌ្ឍជាបន្តបន្ទាប់លើវិស័យជាច្រើន នាំមកនូវផលប្រយោជន៍ជាក់ស្តែងយ៉ាងច្រើន ដល់ប្រជាជននៃប្រទេសទាំងពីរ។

ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានអះអាងថាផងដែរថា ភាគីទាំងពីរនឹងបន្តសម្របសម្រួលជាមួយគ្នាយ៉ាងជិតស្និទ្ធ និងប្រកបដោយប្រសិទ្ធភាព នូវរាល់កិច្ចព្រមព្រៀងកម្រិតខ្ពស់រវាងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃគណបក្ស និងប្រទេសទាំងពីរ។ បន្តពង្រឹងទំនាក់ទំនងភាពជាអ្នកជិតខាងល្អ មិត្តភាពប្រពៃណី សហប្រតិបត្តិការលើគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង ដែលរួមចំណែកដល់ការថែរក្សាសន្តិភាព ស្ថិរភាពកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍនៅក្នុងតំបន់ និងជុំវិញពិភពលោក។

ជាសរុបមក កម្ពុជាពិតជាបានរួមចំណែកយ៉ាងសកម្ម ក្នុងការជួយជ្រោមជ្រែងប្រទេសវៀតណាម ប្រឆាំងរបបចក្រព័ទ្ធនិយម រហូតទទួលបានជោគជ័យនាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្ត និងជំរុញកិច្ចសហប្រតិបត្តិការនេះ ឱ្យមានការរីវឌ្ឍទៅមុខជាបន្តបន្ទាប់ លើគ្រប់វិស័យ និងក្នុងគ្រប់កាលៈទេសៈរហូតមកទល់សព្វថ្ងៃ។ បច្ចុប្បន្ននិងអនាគត ក្នុងតំបន់និងពិភពលោក នៅតែមានការអភិវឌ្ឍប្រកបដោយភាពស្មុគស្មាញ ហើយអនាគតនៃទំនាក់ទំនងអន្តរជាតិ អាចនឹងជួបប្រទះភាពស្មុគស្មាញនិងបញ្ហាប្រឈមជាច្រើនទៀត ប៉ុន្តែយើងអាចបញ្ជាក់បានថា ក្នុងប៉ុន្មានឆ្នាំទៅមុខទៀត កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងកម្ពុជានិងវៀតណាម នឹងនៅតែដើរតាមនិន្នាការវិជ្ជមាន កាន់តែស្និទ្ធស្នាល និងទទួលបានសមិទ្ធផលជាផ្លែផ្កាជាច្រើនបន្តទៀត។



ក្រុមរថយន្តដឹកជញ្ជូននិងកងទ័ពវៀតណាម ក្នុងយុទ្ធនាការហីជីមិញ ឆ្នាំ១៩៧៥ លើខ្សែផ្លូវ Truong Son
(រូបថត: សារមន្ទីប្រវត្តិសាស្ត្រយោធាវៀតណាម)




ផ្លូវលំហូជីមិញនាបច្ចុប្បន្ន (ប្រភព៖ VOV5)

ដោយ៖ លោក អ៊ុច លាង អ្នកសិក្សាស្រាវជ្រាវនៃនាយកដ្ឋានសិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា